# ឡើងមាយនៅប្រាសាទបល្ល័ង្ក

ប្រាសាទបល្ល័ង្ក មានទីតាំងស្ថិតនៅភូមិដងតាឯក ឃុំដូង ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ដែលជាសំណង់ប្រាសាទឥដ្ឋសង់នៅលើគ្រឹះថ្មបាយក្រៀម មានរាងបួនជ្រុងទ្រវែង ហើយមានយ៉មួយលយទៅមុខខាងកើត ពោល ទំនងសង់ឡើងនៅក្នុងរជ្ជកាលព្រះបាទស្រីសូរ្យវរ្ម័នទី១ (គ.ស. ១០០២-១០៤៩)។ បើមើលទៅលើស្ថានភាពបច្ចុប្បន្នរបស់ប្រាសាទ គឺមានលក្ខណៈទ្រុឌទ្រោមគួរឱ្យកត់សម្គាល់ ប៉ុន្តែ ការប្រណិប័តជំនឿរបស់អ្នកស្រុកទៅលើបុរាណដ្ឋាននេះ គឺនៅតែបន្តឥតដាច់នោះឡើយ។ ជាក់ស្តែង ជាទៀងទាត់រៀងរាល់ឆ្នាំ នៅទីនេះគេតែងប្រារព្ធពិធីឡើងមាយនៅថ្ងៃ៣កើត ខែមាឃ (មាឃធំ) ដែលគេសន្មតថាជាថ្ងៃ "**បើកទ្វារស្រុក**" និងប្រារព្ធពិធីបុណ្យភូមិនៅថ្ងៃ៨កើត ខែមាឃ (មាឃធំ) ដែលគេសន្មតថាជាថ្ងៃ "**បិទទ្វារស្រុក**"។ ជាទូទៅ ការហៅថា "ឡើងមាយ" នៅទូទាំងខេត្តកំពង់ធំ គេមិនសូវនិយមហៅនោះទេ ពោល គឺគេច្រើនហៅថា "ឡើងអ្នកតា" ឬ "ឡើងលោកតា"។ ប៉ុន្តែ មួយផ្នែកធំនៃអ្នកស្រុកស្ទោង និងមួយផ្នែកធំនៃអ្នកស្រុកប្រាសាទបល្ល័ង្ក គេហៅពិធីនេះថា "ឡើងមាយ" ពោល គឺហៅដូចអ្នកស្រុកសៀមរាបដូច្នោះដែរ។ តើពិធីឡើងមាយនៅប្រាសាទបល្ល័ង្កមានលក្ខណៈដូចម្តេចខ្លះ? និងមានភាពខុសគ្នាយ៉ាងណាខ្លះពីពិធីឡើងអ្នកតានៅជុំវិញតំបន់ប្រាសាទសំបូរព្រៃគុក?

ពិធីឡើងមាយនៅទីនេះចាប់ផ្តើមនៅម៉ោងប្រមាណ ១ រសៀល នៅខ្ទមអ្នកតាមួយដែលស្ថិតនៅខាងមុខប្រាសាទបល្ល័ង្កផ្ទាល់តែម្តង ដែលក្នុងខ្ទមនោះមានផ្តែរទ្វារធ្វើអំពីថ្មភក់មួយសន្មតថាជា "អ្នកតា"។ មនុស្សដែលមកចូលរួម (កូនស្រុកកូនស្រែ) គឺមកពីភូមិចំនួន ៤ រួមគ្នា គឺភូមិដងតាឯក ភូមិតាមុំ ភូមិក្របៅ និងភូមិដងផ្តៀក ហើយអ្នកស្រុកទាំង៤ភូមិនេះជឿថា កាលណាមិនបានរៀបចំពិធីឡើងមាយនៅប្រាសាទបល្ល័ង្កជូនដល់ចាស់ស្រុកនោះ គេមិនអាចប្រារព្ធពិធីផ្សេងៗទៀតនៅភូមិទាំងនោះឡើយ ព្រោះគេជឿថា "**ចាស់ស្រុក**" ដែលមានខ្ទមស្ថិតនៅខាងមុខប្រាសាទបល្ល័ង្កនេះ គឺជាអមនុស្សដែលមានឫទ្ធិអំណាចធំជាងគេប្រចាំតំបន់ ហើយជាម្ចាស់របស់ប្រាសាទនេះតែម្តង។ គេកាន់ភ្ជាប់ជាមួយមកនូវកក់មួយបាច់ (អ្នកស្រុកហៅថា "**សសិតដំរី**") ដែលគេសន្មតថាជា "**ព្រលឹងស្រូវ**"។ ទំនៀមនេះ ដូចគ្នាទៅនឹងពិធីឡើងអ្នកតារបស់ជនជាតិកួយនៅជុំវិញតំបន់ប្រាសាទសំបូរព្រៃគុកដែរ ដូចជា ភូមិអណ្តាស ភូមិតាឡែក ភូមិកូនក្អែក ភូមិវាលវែង ។ល។ ព្រលឹងស្រូវដែលយកមកនេះ គេមិនបានយកទៅចងផ្អោបនឹងខ្ទមអ្នកតា ឬដោតនៅជុំវិញខ្ទមអ្នកតាដូចដែលធ្លាប់ឃើញនៅភូមិផ្សេងៗឡើយ។ ប៉ុន្តែ គេយកមកដាក់នៅធុងរួមមួយនៅខាងក្នុងខ្ទម

អត្ថបទដោយ៖ ខន វុទ្ធី

អ្នកតានៅក្នុងបញ្ជាន់រូប នៅជិតចុងបញ្ចប់នៃពិធី ដើម្បីស្រូបយកកម្លាំងថាមពលពីអ្នកតា ហើយព្រលឹងស្រូវនេះគេកាន់ទៅផ្ទះវិញដើម្បីដោតជាប់នឹងច្រមសសរកន្ទោងផ្ទះ និងដោតជាប់ជាមួយដោកស្រូវ ក្នុងបំណងសូមឱ្យសុខសប្បាយ និងផលស្រូវឆ្នាំក្រោយកើតកាលវាលគុម្ពឬរីកដុះដាលបានល្អ។ គួរកត់សម្គាល់មួយទៀត សំណែនសម្រាប់បញ្ជូនដល់ពពួកខ្មោចព្រៃតិរិច្ឆាន គេមិនទម្លាប់រៀបចំជាមាន់ក្តាង ខ្ទោះខ្ទៀង សាលា កៅអី ពែរាប ពែច្រមុះជ្រូក ពែកញ្ច្រោង រទេះគោ រទេះក្របី រូបដំរី រូបសេះ អ្វីច្រើននោះឡើយ ពោល គឺគ្រាន់តែមានសង្ឃឹកមួយធ្វើអំពីស្រទបចេកមានរាងបួនជ្រុងទ្រវែង ប៉ុន្តែ គេធ្វើរូបយន្តហោះ រូបគោ ក្របី សេះ ជ្រូក មាន់ ទា ដែលធ្វើអំពីក្រដាសឡាំងដោតជាប់នៅជុំវិញសង្ឃឹកនោះ ដែលសុទ្ធសឹងជានិម្មិតរូបនៃយានសម្រាប់បញ្ជូនឬបណ្តេញពពួកខ្មោចព្រៃតិរិច្ឆានទាំងនោះឱ្យចេញពីស្រុក តាមរយៈកម្លាំងថាមពលរបស់អ្នកតា។

បន្ទាប់អំពីកិច្ចសែនព្រេនបានបញ្ចប់ កិច្ចបញ្ជាន់រូបក៏ចាប់ផ្តើមឡើងតែម្តង ដោយមានអ្នកភ្លេងអារក្សមួយក្រុមមានគ្នាចំនួន ៤ នាក់ (ទ្រសោ១ និងស្គរ៣) សម្រាប់ប្រគុំអន្ទងអមនុស្សឱ្យមកសណ្ឋិតក្នុងខ្លួនរូបស្នង។ រូបស្នងនៅទីនេះមានទាំងរូបប្រុសនិងស្រី ដែលភាគច្រើនជាមនុស្សស្ថិតនៅក្នុងវ័យចំណាស់។ គេជឿថាអ្នកតាដែលជាឃុំគ្រងតំបន់នេះមានចំនួនដល់ទៅ ១២១ ឯណោះ ប៉ុន្តែ អ្នកតាដែលមានឫទ្ធិអំណាចធំជាងគេ គេហៅថា "**ចាស់ស្រុក**" ដែលជាម្ចាស់ប្រាសាទ និងជាអតីតមេទ័ពមួយរូបនាសម័យបុរាណដែលមានកាន់ដាវមួយផង។ រីឯ អ្នកតាសំខាន់ៗផ្សេងទៀតមានដូចជា តាគង់ តាពៅ យាយទាប យាយណាក់ តាម៉ឺនមាស តាថាន់ (មេទ័ព) យាយអ៊ែម កុមាររាជ តាពេជ្រ តាតិលមិល ។ល។ បទចម្រៀងក្នុងកិច្ចបញ្ជាន់រូប មានបទអញ្ជើញគ្រូ បទតារ៉ា បទតាថាវ បទអ្នក បទសុរិយា បទអន្ទង បទអុំទូក និងបទបំពេញឃ្លាំង។ គួរកត់សម្គាល់ កិច្ចសន្ទនារវាងកូនស្រុកកូនស្រែជាមួយអ្នកតាតាមរយៈរូបស្នងនៅក្នុងកិច្ចបញ្ជាន់រូបនាឆ្នាំ២០២៦នេះ គឺច្រើនជាប់ពាក់ព័ន្ធជាមួយបញ្ហាប្រទេសជាតិ ច្រើនជាងបញ្ហាភោគផលស្រូវ និងការព្យាបាលជំងឺ។ ដ្បិតយើងដឹងស្រាប់ហើយថា ភាពតានតឹងផ្នែកយោធារវាងខ្មែរ-សៀមកំពុងតែក្តៅគគុកនៅឡើយ។ ម៉្លោះហើយ កូនស្រុកកូនស្រែបានយកក្តីព្រួយបារម្ភនេះមកសួរនាំ និងជម្រាបជូនអមនុស្សឱ្យបានដឹងឮ ហើយស្នើសុំមកវិញនូវការសំណូមពរឱ្យអ្នកតាជួយឃុំគ្រងថែរក្សាប្រទេសកម្ពុជាឱ្យសុខសាន្តតរៀងទៅ ព្រមទាំងស្នើសុំឱ្យអ្នកតាជួយថែរក្សាយោធិនកំពុងស្ថិតនៅសមរភូមិមុខមួយចំនួនដែលជាអ្នកមានស្រុកកំណើតនៅតំបន់នេះផ្ទាល់។ ត្រង់ចំណុចនេះ បង្ហាញឱ្យឃើញថា មនុស្សចាត់ទុកអ្នកតា គឺជាមេកើយរបស់ស្រុក ដែលអាចពឹងពាក់បានសព្វគ្រប់បែបយ៉ាង ទោះបីតួនាទីសំខាន់របស់អ្នកតាជាប់ពាក់ព័ន្ធជាមួយភោគផលស្រូវក៏ដោយ។

អត្ថបទដោយ៖ ខន វុទ្ធី

គួរកត់សម្គាល់ជាពិសេស កិច្ចចុងក្រោយនៃពិធីឡើងមាយនៅប្រាសាទបល្ល័ង្គនេះ គឺគេបានប្រមូលព្រលឹងស្រូវពីកូនស្រុកកូនស្រែ យកមកដាក់ក្នុងធុងរួមមួយនៅកណ្តាលរោងអ្នកតា។ ពេលនោះ រូបស្នងអ្នកតាទាំងអស់ឡើងរាំផង និងប្រោះព្រំទឹកដល់ព្រលឹងស្រូវនៅក្នុងធុងនោះផង ដែលសបញ្ជាក់ឱ្យឃើញថា គឺជាការផ្ទេរថាមពលពិសិដ្ឋរបស់អ្នកតាស្រូបចូលទៅក្នុងព្រលឹងស្រូវ ក្នុងនិម្មិតរូបសូមឱ្យព្រលឹងស្រូវនោះ អាចចែកចាយថាមពលពិសិដ្ឋទៅដល់ស្រូវរបស់អ្នកស្រុកពោល គឺសូមឱ្យការបង្កបង្កើនផលស្រូវនារដូវបន្ទាប់ បានកើតកាលវាលគុម្ពចម្រុងចម្រើនដូច្នេះឯង។ ស្របពេលជាមួយគ្នានោះ រូបស្នងដែលកំពុងស្ថិតនៅក្នុងពេលអ្នកតាចូលសណ្ឋិតនោះ បានស្រែកជាសំឡេងសត្វសេះ ដើម្បីជាសញ្ញាហៅបរិវារជិះសេះចូលមក។ អ្នកជិះសេះក៏ចូលមកជិតសង្ឃឹកដែលត្រៀមបញ្ជូនចេញក្រៅ រួមជាមួយអ្នកផ្ទុំកញ្ចែម្នាក់មកជាមួយផង។ សេះដែលគេយកមកជិះនោះ គឺគ្រាន់តែជាសេះនិម្មិតរូបប៉ុណ្ណោះដែលធ្វើឡើងអំពីស្លឹកអន្សែ ហើយការជិះសេះនោះទៀតសោតជានិម្មិតរូបបង្ហាញថា ការបណ្តេញពពួកខ្មោចព្រៃតិរច្ឆានឱ្យចេញពីស្រុក គឺតែងមានមធ្យោបាយដឹកជញ្ជូនចេញទៅជាច្រើន រីឯការផ្លុំកញ្ចែទៀតសោត ក៏ជានិម្មិតរូបបង្ហាញអំពីការបណ្តេញឧបទ្រពចង្រៃឱ្យចេញពីស្រុកដូចគ្នា។ ព្រមជាមួយគ្នានេះ សេះនោះទៀតសោត គឺជាមធ្យោបាយហែរហមអមនុស្ស (អ្នកតា) ទៅកាន់ទីតាំងដើមវិញ ព្រោះទីតាំងប្រារព្ធពិធីស្ថិតនៅខ្ទមអ្នកតាចាស់ស្រុក រីឯអ្នកតាដែលមកចូលរួមពិធីដែលកូនស្រុកកូនស្រែរៀបចំជូននេះ គឺមានប្រភពមកពីទីតាំងជុំវិញជាច្រើនកន្លែង ម៉្លោះហើយត្រូវការបរិវារហែរហមទៅវិញ។ រណ្តាប់បញ្ជូននៅលើសង្ឃឹកនោះ គេយកទៅដាក់នៅទីស្រែដែលស្ថិតនៅទិសពាយព្យកន្លែងប្រារព្ធពិធី ហើយកន្លែងដែលដាក់នោះស្ថិតនៅចំផ្លូវបំកជាបួន ដែលជានិម្មិតរូបបង្ហាញថា សូមឱ្យពពួកខ្មោចព្រៃតិរច្ឆានទាំងឡាយអាចចាកចេញពីស្រុកទៅតាមផ្លូវគ្រប់ច្រកល្ហក។ ទំនៀមនេះ ជាលក្ខណៈពិសេសដាច់ដោយឡែកមួយរបស់អ្នកស្រុកនៅតំបន់នេះ ហើយមានលក្ខណៈស្រដៀងទំនៀមនៅភូមិចុងព្រៃនិងភូមិព្រៃព្រះ (ប៉ែកនិរតីតំបន់ប្រាសាទសំបូរព្រៃគុក) ដែលកិច្ចបញ្ជូនធ្វើឡើងដោយអ្នកតាជិះដំរី ពោល គឺអ្នកតាបានជ្រើសរើសកូនស្រុកកូនស្រែម្នាក់ឱ្យមកលត់ជង្គង់ដើរតួជាសត្វដំរី។

សរុបជារួមមក ពិធីឡើងមាយនៅប្រាសាទបល្ល័ង្គ បានឆ្លុះបញ្ចាំងឱ្យឃើញទំនាក់ទំនងរវាងជំនឿជីវចលរបស់អ្នកស្រុក ជាមួយប្រាសាទដែលជាសំណង់ឧទ្ទិសដល់ព្រហ្មញ្ញសាសនា។ ពោល គឺមានន័យថា ទោះបីផ្នត់គំនិតនៃជំនឿព្រហ្មញ្ញសាសនាបានចុះថយទៅហើយក្តី អ្នកស្រុក

អត្ថបទដោយ៖ ខន វុទ្ធី

នៅតែយល់ថា សំណង់ប្រាសាទនេះគឺមានម្ចាស់ថែរក្សា ដែលគេចាត់ទុកជាអ្នកតាចាស់ស្រុក ឬជាមេកើយរបស់ស្រុក និងមានតួនាទីឃុំគ្រងថែរក្សាការពារកូនស្រុកកូនស្រែ ហើយមានមុខងារជាប់ពាក់ព័ន្ធជាមួយស្រែ ជាទីប្រជុំភោគផល ជាលំនឹងភោគផលកសិកម្ម ពោល គឺជាអ្នកដែលបានផ្តល់នូវទឹកភ្លៀងពេញបរិបូណ៌សម្រាប់ស្រោចស្រពដល់ដំណាំកសិកម្មរបស់អ្នកស្រុក។

## បញ្ជីឯកសារពិគ្រោះ


**ម៉ង់ រ៉ាលី, អាន រស្មី, ស្រី សមប៊ុនណារ៉ុង**

២០២៥, *មត៌កអរូបីជុំវិញតំបន់សំបូរព្រៃគុក (ការសិក្សាស្រាវជ្រាវ និងចុះបញ្ជីកិច្ចពិធីបែបជីវចល)*, ភ្នំពេញ។

**ម៉ៅ សិទ្ធិប៊ុណារឌ្ឍន៍**

២០១៥, *ការកំណត់ និងប្រើប្រាស់លំហ*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី ២៣ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

**ស្រេង ជីវ័ន្ត**

២០២៥, *សញ្ញាណ "ស្នង" ក្នុងកិច្ចពិធី*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា, ជំនាន់ទី៣៣, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

**ហៀន សុវណ្ណមរកត**

"ឡើងមាឃ ទំនៀមអ្នកស្រុកអង្គរ", អត្ថបទផ្សាយអនឡាញនៅក្នុង *AMS Khmer civilization*, https://khmercivilization.ams.com.kh/detail/26231 ។

**អាំង ជូលាន**

២០១២-២០១៣, "៣កើតមាឃធំ", *បណ្តាញព័ត៌មានក្នុងវប្បធម៌ខ្មែរ*, ៨: ៤៣-៤៤។

**ANG Chouléan**

1986, *Les êtres surnaturels dans la religion*, Cedoreck, Paris.



រូបលេខ១៖ ប្រាសាទបល្ល័ង្ក




រូបលេខ២៖ ផ្តែរទ្វារថ្មភក់ដាក់ក្នុងខ្ទមអ្នកតា



រូបលេខ៣៖ ទិដ្ឋភាពមនុស្សមកជួបជុំពិធីឡើងមាយ



រូបលេខ៤៖ អ្នកចូលរួមកាន់ព្រលឹងស្រូវមករោងពិធី

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ខន វុទ្ធី



រូបលេខ៥៖ កិច្ចបញ្ជាន់រូប



រូបលេខ៦៖ កិច្ចបញ្ជាន់រូប





រូបលេខ៧-៨៖ កិច្ចសន្ទនារវាងកូនស្រុកកូនស្រែជាមួយអ្នកតា





រូបលេខ៩-១០៖ កិច្ចសន្ទនារវាងកូនស្រុកកូនស្រែជាមួយអ្នកតា និងការស្តោះផ្លុំជូនដល់កូនស្រុកកូនស្រែ

អត្ថបទដោយ៖ ខន វុទ្ធី



រូបលេខ១១៖ អ្នកតាប្រោះព្រំដល់ព្រលឹងស្រូវ



រូបលេខ១២៖ សង្ឃ្រឹកបញ្ជូន



រូបលេខ១៣៖ សេះនិម្មិតរូបក្នុងកិច្ចបញ្ជូន



រូបលេខ១៤៖ សែងរណ្ដាប់បញ្ជូនទៅកាន់ទីស្រែ



រូបលេខ១៦៖ អ្នកស្រុកប្រមូលព្រលឹងស្រូវទៅផ្ទះ

អត្ថបទដោយ៖ ខន វុទ្ធី